ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
លេខចូល 2048
ថ្ងៃទី: 4. 6. 24 ម៉ោង 9: 45
បញ្ជូន: ថ្ងៃទី:

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១២១ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និងសម្របសម្រួលគម្រោងអភិវឌ្ឍន៍ផ្លូវដែក នៅកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលមាត្រា ៥០ មាត្រា ៥១ មាត្រា ៥២ និងមាត្រា ៥៣ នៃអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១.-**

បង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និងសម្របសម្រួលគម្រោងអភិវឌ្ឍន៍ផ្លូវដែកនៅកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** | ឧបនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ស៊ុន ចាន់ថុល** | ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាប្រធាន<br>ក្រុមប្រឹក្សាជាតិកស្តុភារកម្ម | អនុប្រធាន |
| ៣- ឯកឧត្តម **ប៉េង ពោធិ៍នា** | រដ្ឋមន្ត្រីក្រសួងសាធារណការ<br>និងដឹកជញ្ជូន | អនុប្រធាន |
| ៤- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ៥- រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | | សមាជិកប្រចាំការ |
| ៦- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងការពារជាតិ | | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងផែនការ | | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | | សមាជិក |
| ១៧- រដ្ឋលេខាធិការក្រសួងបរិស្ថាន | | សមាជិក |
| ១៨- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | សមាជិក |
| ១៩- អភិបាល នៃគណៈអភិបាលរាជធានី-ខេត្តពាក់ព័ន្ធ | | សមាជិក។ |

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការជាតិគ្រប់គ្រង និងសម្របសម្រួលគម្រោងអភិវឌ្ឍន៍ផ្លូវដែកនៅកម្ពុជា ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមការស្នើសុំរបស់ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង និងសម្របសម្រួលគម្រោងអភិវឌ្ឍន៍ផ្លូវដែកនៅកម្ពុជា។



ៗ

**មាត្រា២._**

គណៈកម្មាធិការជាតិគ្រប់គ្រង និងសម្របសម្រួលគម្រោងអភិវឌ្ឍន៍ផ្លូវដែកនៅកម្ពុជា មានភារកិច្ចៈ

-ពិនិត្យ និងផ្តល់យោបល់លើក្របខ័ណ្ឌគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការមេ នៃការអភិវឌ្ឍផ្លូវដែក និងការធ្វើប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវដែកទូទាំងប្រទេស

-ដឹកនាំ និងតម្រង់ទិសជាយុទ្ធសាស្ត្រលើការអនុវត្តគម្រោងអភិវឌ្ឍន៍ផ្លូវដែក និងការធ្វើប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវដែក

-ធ្វើរបាយការណ៍វាយតម្លៃ និងបូកសរុបវឌ្ឍនភាពការងារជូនប្រមុខរាជរដ្ឋាភិបាលជ្រាប ឬ/និងស្នើសុំការសម្រេច។

**មាត្រា៣._**

គណៈកម្មាធិការជាតិគ្រប់គ្រង និងសម្របសម្រួលគម្រោងអភិវឌ្ឍន៍ផ្លូវដែកនៅកម្ពុជា មានសេនាធិការដូចខាងក្រោមៈ

១) ក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីជំរុញការអភិវឌ្ឍផ្លូវដែកនៅកម្ពុជា ជាសេនាធិការលើការសិក្សា និងការរៀបចំផែនការមេអភិវឌ្ឍន៍ផ្លូវដែកនៅកម្ពុជា។

២) ក្រសួងសាធារណការ និងដឹកជញ្ជូន ជាសេនាធិការលើការងារដឹកនាំ និងគ្រប់គ្រងលើការងារសិក្សា ការងារសាងសង់ និងការធ្វើប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវដែក។

៣) គណៈកម្មការអន្តរក្រសួងចរចាកិច្ចព្រមព្រៀងសម្បទានផ្លូវដែក ជាសេនាធិការលើការងាររៀបចំ និងចរចាកិច្ចព្រមព្រៀងសម្បទានផ្លូវដែកជាមួយក្រុមហ៊ុនសម្បទានិក។

**មាត្រា៤._**

គណៈកម្មការអន្តរក្រសួងចរចាកិច្ចព្រមព្រៀងសម្បទានផ្លូវដែកត្រូវមានសមាសភាពដូចខាងក្រោមៈ

១) រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ជាសហប្រធាន

២) រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសហប្រធាន

៣) តំណាងក្រុមប្រឹក្សាជាតិកស្តុការកម្ម ជាអនុប្រធាន

៤) តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន មួយចំនួនតាមការចាំបាច់ ជាសមាជិក

៥) តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយចំនួនតាមការចាំបាច់ ជាសមាជិក

៦) តំណាងក្រុមប្រឹក្សាជាតិកស្តុការកម្ម មួយចំនួនតាមការចាំបាច់ ជាសមាជិក។

**មាត្រា៥._**

គណៈកម្មាធិការជាតិគ្រប់គ្រង និងសម្របសម្រួលគម្រោងអភិវឌ្ឍន៍ផ្លូវដែកនៅកម្ពុជា មានអគ្គលេខាធិការដ្ឋានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន។

**មាត្រា៦._**

គណៈកម្មាធិការជាតិគ្រប់គ្រង និងសម្របសម្រួលគម្រោងអភិវឌ្ឍន៍ផ្លូវដែកនៅកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង និងសម្របសម្រួលគម្រោងអភិវឌ្ឍន៍ផ្លូវដែកនៅកម្ពុជា អាចអញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ ឬអ្នកបច្ចេកទេសដទៃទៀត ចូលរួមប្រជុំ តាមការចាំបាច់។

**មាត្រា៧.**_

គណៈកម្មាធិការជាតិនេះ អាចបង្កើតគណៈកម្មការ អនុគណៈកម្មការ ឬក្រុមការងារមួយចំនួន តាមការចាំបាច់។

**មាត្រា៨.**_

អនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រង និងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា អនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា៣ នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រង និងសម្របសម្រួលគម្រោងផ្លូវដែកនៅកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.**_

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាជាតិភស្តុភារកម្ម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៧ រោច ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ